## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១២

## ជប៉ុនផ្ដល់ ១០០,២៩៨ ដុល្លារអាមេរិក សម្រាប់ការសាងសង់អគារមន្ទីរពេទ្យ និងបំពាក់សម្ភារៈបរិក្ខារពេទ្យ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្ដល់ទឹកប្រាក់សរុបចំនួន ១០០,២៩៨ដុល្លាអាមេរិកដល់អង្គការជួយសេវាពេទ្យកម្ពុជាសម្រាប់គម្រោងសាងសង់អគារមន្ទីរពេទ្យ និងបំពាក់សម្ភារៈបរិក្ខារពេទ្យក្នុងមន្ទីរពេទ្យបង្អែកស្រុកបរកែវខេត្តរតនគីរី។ កិច្ចសន្យាផ្ដល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយឯកឧត្តមម៉ាសាហ៊្វូមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក ឈ ភឿន ប្រធានអង្គការជួយសេវាពេទ្យកម្ពុជានៅស្ថានទូតជប៉ុន។




ដើម្បីបង្កើនសេវាសុខាភិបាលក្នុងខេត្តរតនគីរី អង្គការជួយសេវាពេទ្យកម្ពុជានឹងអនុវត្តគម្រោងសាងសង់អគារមន្ទីរពេទ្យដែលមាន៦បន្ទប់សម្រាប់ផ្នែកជំងឺកុមារផ្នែកសម្រាកព្យាបាល ផ្នែកបន្ទប់ពិសោធន៍ និងបន្ទប់បុគ្គលិក ព្រមទាំងការបំពាក់សម្ភារៈបរិក្ខារពេទ្យដូចជាមីក្រូទស្សន៍និងម៉ាស៊ីនបង្វិលឈាមក្នុងមន្ទីរពេទ្យបង្អែកស្រុកបរកែវ។ ប្រជាជនប្រមាណ ៥០,០០០ នាក់ដែលរស់នៅក្នុងស្រុកបរកែវ ស្រុកអូយ៉ាដាវ និង ស្រុកអណ្ដូងមាសនឹងទទួលបានអត្ថប្រយោជន៍ពីសេវាសុខាភិបាលដែលផ្ដល់ដោយមន្ទីរពេទ្យនេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាល ជប៉ុន បានចាប់ផ្ដើមតាំងពី ឆ្នាំ១៩៩១ ដើម្បីគាំទ្រ ដល់ កិច្ចខិតខំប្រឹងប្រែង របស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្ថាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជន

ងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រ  និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្ដីថ្លៃថ្នូររបស់ពួកគេក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្ដល់ថវិកាជាង៤៨.៣លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៨០គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*